# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ទៅជាថ្នាក់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣៩អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ស ម្រេ ច

**មាត្រា ១.-**

ដំឡើង " មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា អក្សរកាត់ " ម.ម.ឧ.ក " ឱ្យមានថ្នាក់ស្មើ នាយកដ្ឋាន ចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២.-**

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- វិភាគ ធ្វើតេស្ត ផ្នែករូបសាស្ត្រ គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិក ដើម្បីកំណត់គុណភាព និងលក្ខណៈ វិនិច្ឆ័យរបស់ផលិតផល
- ធ្វើព្យាសកម្មឧបករណ៍ខ្នាតដែលប្រើប្រាស់ក្នុងផ្នែកនីត្យានុកូលមាត្រាសាស្ត្រ វិទ្យាសាស្ត្រមាត្រាសាស្ត្រ និង មាត្រាសាស្ត្រឧស្សាហកម្ម ដើម្បីធានាភាពត្រឹមត្រូវ សុចរិត
- រក្សាទុកស្តង់ដារមាត្រាសាស្ត្រ រួមមានស្តង់ដារគោលជាតិ និងស្តង់ដារបន្ទាប់

- សហការរៀបចំបញ្ចូលប្រព័ន្ធឯកតាមាត្រាសាស្ត្រគ្រប់លំដាប់ថ្នាក់អនុលោមតាមប្រព័ន្ធឯកតាអន្តរជាតិ
- បណ្តុះបណ្តាល លើកកំពស់សមត្ថភាពវិភាគ ធ្វើតេស្តលើផលិតផល និងព្យាសកម្មឧបករណ៍ខ្នាតមាត្រាសាស្ត្រ
- សហការស្រាវជ្រាវ ផ្សព្វផ្សាយ និងផ្តល់យោបល់ ពីគុណភាព សុវត្ថិភាពផលិតផលបច្ចេកវិជ្ជាក្នុងការកែច្នៃ ការរក្សាទុក និងបង្កើតផលិតផលថ្មី
- សហប្រតិបត្តិការជាមួយមន្ទីរពិសោធន៍នៃស្ថាប័នជាតិ និងអន្តរជាតិ
- បង្កើនសមត្ថភាពមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជាឱ្យទទួលបានការវាយតម្លៃទទួលស្គាល់ពីជាតិ និងអន្តរជាតិ ។

**មាត្រា ៣.-**

មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ត្រូវបានដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦ "ដើម្បីអនុវត្តន៍"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*